ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

# របាយការណ៍សង្ខេប
# ស្ដីពី
# សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា
# នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៥

សម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៥ បានបញ្ចប់នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២៥។

នាចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ ដែលមានរយៈពេល៣ខែនេះ ថ្នាក់ដឹកនាំ គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការ ក្រុមភូមិភាគ ក្រុមសមាជិកាព្រឹទ្ធសភា និងសមាជិក សមាជិកា ព្រឹទ្ធសភា បានខិតខំបំពេញការងារជាប្រក្រតីក្នុងព្រឹទ្ធសភា និងចុះប្រាស្រ័យទាក់ទងជាមួយ ប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិភាគយ៉ាងសកម្ម ស្របតាមការកំណត់ក្នុងប្រការ៥៥ នៃ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា។

ក្នុងនាមគណៈកម្មាធិការអចិន្ត្រៃយ៍ ទូលព្រះបង្គំជាខ្ញុំ សូមអនុញ្ញាតរាយការណ៍ដោយសង្ខេបជូន អង្គព្រឹទ្ធសភាជ្រាបអំពីសកម្មភាពការងារសំខាន់ៗរបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំទាំង២ ដូចតទៅ៖

## I- សកម្មភាពការងារទូទៅ

### ១- ការងារថ្នាក់ដឹកនាំព្រឹទ្ធសភា

ដោយអនុវត្តតាមការកំណត់នៃរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ថ្នាក់ដឹកនាំព្រឹទ្ធសភា បានយកចិត្តទុកដាក់បំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដូចខាងក្រោម៖

១.១- សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ៖

- បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្ដីទី ចំនួន១លើក ដែលក្នុងឱកាសនោះ សម្ដេចតេជោ បាន៖
  - ទទួលសារតាំងពី ឯកឧត្តម ធុល ត្រៃសូរ៉ាត់ (Tull TRAISORAT) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រថៃឡង់ដ៍ ប្រចាំព្រះរាជាណាចក្រកម្ពុជា នាព្រឹក ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៥។
  - ផ្ញើសារលិខិតចូលរួមរំលែកទុក្ខជូនលោកជំទាវ ផែថងថាន ស៊ីណាវ៉ាត់ នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រថៃឡង់ដ៍ និងឯកឧត្តម នាយឧត្តមសេនីយ៍ជាន់ខ្ពស់ មីន អោងឡាំង ចំពោះការបាត់បង់អាយុជីវិតប្រជាជន ការរងរបួស និងការបំផ្លិចបំផ្លាញនានា ដែលបង្ក ឡើងដោយគ្រោះរញ្ជួយដីធ្ងន់ធ្ងរ។
  - (ក) ចុះហត្ថលេខាលើសំណើសុំប្រទានព្រះរាជតម្រិះ ចំនួន១៤៨ (ខ) ទទួលព្រះរាជសារ ព្រះរាជទានសិទ្ធិ ចំនួន១៤៨ (គ) ចុះហត្ថលេខាលើព្រះរាជក្រឹត្យ ចំនួន១៥៩ (ឃ) ចុះ ហត្ថលេខាលើលិខិតផ្សេងៗ ចំនួន៥៣ (ង) ជ្រាបជាព័ត៌មាន ចំនួន១៤៥ និង (ច)ចុះ ហត្ថលេខាលើសេចក្ដីសម្រេច និងឯកសារនានា ចំនួន៣៦ ។

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: secretariat@senate.gov.kh

- អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងដឹកនាំប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន១លើក។
- បានអញ្ជើញជាអធិបតី និងអញ្ជើញចូលរួមក្នុងពិធីនានា ចំនួន៦លើក រួមមាន៖
  - អញ្ជើញថ្វាយ និងទទួលព្រះរាជដំណើររបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ក្នុងព្រះរាជពិធីសម្ពោធមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា នៅវត្តឧណ្ណាលោម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។
  - អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីមីទិ្ទញអបអរសាទរខួបលើកទី៤៦ នៃទិវាជ័យជម្នះ ៧ មករា ១៩៧៩- ៧ មករា ២០២៥ នៅមជ្ឈមណ្ឌលកោះពេជ្រ។
  - អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានានៅក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
  - អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីពិសាភោជនាហារសាមគ្គីនៃគ្រួសារសមាគមឧកញ៉ាកម្ពុជា ក្នុងឱកាសនៃពិធីបិទសន្និបាតប្រចាំឆ្នាំបូកសរុបលទ្ធផលការងារឆ្នាំ ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់សមាគមឧកញ៉ាកម្ពុជា នៅដីព្រៃមៀ សែនជ័រសែនសុខ។
  - អញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបំពាក់ឋានន្តរសក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស ៥ នៃកងយោធពលខេមរភូមិន្ទជូន **សម្តេចពិជ័យសេនា ទៀ បាញ់** និង**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ។
  - អញ្ជើញរៀបចំចាត់ចែងពិធីបុណ្យសព **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្តេចតេជោ**។

**១.២- ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ ព្រឹទ្ធសភា ៖**

- បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន៣លើក។
- បានអញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន៣លើក។
- បានអញ្ជើញដឹកនាំ និងចូលរួមប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ ចំនួន២លើក។
- បានអញ្ជើញចូលរួមកិច្ចប្រជុំរួមរវាងតំណាងព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញស្តីពី សេចក្តីព្រាងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៅសាលប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ។
- បានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ (ខេត្តត្បូងឃ្មុំ និងកំពង់ចាម) ចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព នៅតាមបណ្តាឃុំនីមួយៗ នៃក្រុងសួង ស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកក្រូចឆ្មារ និងស្រុកតំបែរ ក្នុងខេត្តត្បូងឃ្មុំ ចំនួន៩លើក ដោយមានអ្នកចូលរួម ចំនួន ៦១២នាក់។ ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តម អនុប្រធានទី១ ព្រឹទ្ធសភា** រួមដំណើរដោយ សមាជិក សមាជិកា ព្រឹទ្ធសភា បាននាំយកអំណោយជាឱសថ និងបរិក្ខារពេទ្យ ដែលជាអំណោយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េ ជូនដល់មន្ទីរពេទ្យបង្អែកត្បូងឃ្មុំ-សួង និងមន្ទីរពេទ្យបង្អែកអូររាំងឪ

នៃខេត្តត្បូងឃ្មុំ និងមន្ទីរពេទ្យបង្អែកកំពង់សៀម-កំពង់ចាម មន្ទីរពេទ្យបង្អែកជើងព្រៃ មន្ទីរពេទ្យបង្អែកព្រៃឈរ មន្ទីរពេទ្យបង្អែកកងមាស និងមន្ទីរពេទ្យបង្អែកកោះសូទិន នៃខេត្តកំពង់ចាម។

- បានណែនាំ និងចាត់សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទីប្រឹក្សា និងមន្ត្រីខុទ្ទកាល័យ **ឯកឧត្តម អនុប្រធានទី១ ព្រឹទ្ធសភា** ចុះជួបសំណេះសំណាល ពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ចំនួន២លើក សរុបចំនួន២៦៩នាក់ នៅខេត្តត្បូងឃ្មុំ ព្រមទាំងចុះពិនិត្យការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធនានា ចំនួន៦លើក នៅខេត្តត្បូងឃ្មុំ និងនៅខេត្តកំពង់ចាម។
- ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា ទទួលជួបគណៈប្រតិភូនារី ចំនួន២៥០នាក់ ដឹកនាំដោយ **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ «**សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប**»។
- បានអញ្ជើញជាអធិបតី និងអញ្ជើញចូលរួមក្នុងពិធីនានា នៅតាមបណ្តាខេត្ត និងរាជធានីភ្នំពេញ រួមមាន៖
  - អញ្ជើញចូលរួមក្នុងព្រះរាជពិធីសម្ពោធមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្ត្រាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានាក្រោមព្រះរាជាអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។
  - អញ្ជើញចូលរួមក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានាក្នុងបរិវេណវត្តព្រះគន្ធសាមគ្គីធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
  - អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបំពាក់ឋានន្តរសក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស ៥ នៃកងយោធពលខេមរភូមិន្ទជូន **សម្តេចពិជ័យសេនា ទៀ បាញ់** និង**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា។
  - អញ្ជើញជូន និងទទួលដំណើរ **សម្តេចតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចនៅ (១) សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង (២) សាធារណរដ្ឋសង្គមនិយមវៀតណាម។
  - អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសពឯក**ឧត្តមអ្នកឧកញ៉ា ឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្តេចតេជោ**។

- អញ្ជើញជួបសំណេះសំណាលជាមួយសមាជិកាព្រឹទ្ធសភា មន្ត្រីរាជការជាស្ត្រី និងនិវត្តជនជាស្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរខួបលើកទី១១៤ ទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ «**សិទ្ធិ សមភាព និងភាពអង់អាច ចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប**»។
- អញ្ជើញចុះពិនិត្យការដ្ឋានស្ថាបនាស្ពានបេតុងអាម៉េ ប្រវែង១០៨ម៉ែត្រ ទទឹង១០ម៉ែត្រ ឆ្លងកាត់ព្រែកប្រាសាទ ដែលសាងសង់ដោយកងកម្លាំងប្រតិបត្តិការរបស់មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម និងបានអញ្ជើញសំណេះសំណាលនិងចែកអំណោយជូនប្រជាពលរដ្ឋឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល ចំនួន ៥៤៦គ្រួសារ។
- អញ្ជើញជាអធិបតី ក្នុងពិធីប្រកាសតែងតាំងអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយស្រុកបាធាយ និងជាប្រធានក្រុមការងារចុះជួយឃុំជើងព្រៃ និងជួបសំណេះសំណាលជាមួយមន្ត្រីរាជការ ក្រុមប្រឹក្សាស្រុក អភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ ប្រធានសមាគមក្រុមប្រឹក្សាស្រុក ឃុំ នាយប៉ុស្តិ៍នគរបាលឃុំ ស្មៀនឃុំ ប្រធានមណ្ឌលសុខភាព លោកគ្រូ អ្នកគ្រូ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋានស្រុក ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម សរុបចំនួន ៤៨៥នាក់។
- អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជាកញ្ចប់អាហារស្រាយបួសខែរ៉ាម៉ាឌនចំនួន ៣០០គ្រួសារ នៅភូមិច្រកបង្គង ភូមិអូរយួន ភូមិស្ពានទីបី ភូមិបូសកន្ទួត ស្ថិតក្នុងស្រុកស្ទឹងត្រង់ ព្រមទាំងបានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ផ្តល់ជូនអាជីវកររងគ្រោះដោយអគ្គីភ័យចំនួន ១៧គ្រួសារ នៅភូមិទី៨ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម។
- អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការរវាងគណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង និងអង្កេតនៃព្រឹទ្ធសភា ជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន។
- បានអញ្ជើញចូលរួមពិសាភោជនាហារក្នុងពិធីផ្លូវការ ចំនួន២លើក។

១.៣- ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ ព្រឹទ្ធសភា ៖

- បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចំនួន១លើក។
- បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន៣លើក និងចូលរួមសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន២លើក។
- បានអញ្ជើញជួបប្រជុំជាមួយថ្នាក់ដឹកនាំនៃវិទ្យាស្ថានស្ថិតិ និងថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា។
- បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារចំនួន២លើក ជាមួយប្រធានគណៈកម្មការទាំង១០នៃព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំវេទិកាពាក់ព័ន្ធនឹងវិស័យផ្សេងៗ

ការរៀបចំផែនការប្រចាំឆ្នាំនិងប្រចាំនីតិកាល និងពិភាក្សាអំពីបញ្ហាប្រឈម និងសំណូមពរក្នុងការអនុវត្តមុខងារតំណាង និងគណនេយ្យភាពជាមួយអង្គបោះឆ្នោត។

- បានអញ្ជើញចុះជួបសំណេះសំណាល ចំនួន៣លើក ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ សរុបចំនួន៥៧៧នាក់ មកពី១០៥សង្កាត់នៃខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌកំបូល ខណ្ឌសែនសុខ ខណ្ឌមានជ័យ ខណ្ឌដូនពេញ ខណ្ឌបឹងកេងកង ខណ្ឌចំការមន ខណ្ឌទួលគោក ខណ្ឌច្បារអំពៅ ខណ្ឌជ្រោយចង្វារ ខណ្ឌឫស្សីកែវ និងខណ្ឌព្រែកព្នៅ។
- បានអញ្ជើញជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍ និងស្ថាប័នកសិកម្មនៅកម្ពុជា។
- បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យពិនិត្យមាត់ធ្មេញជូនដល់សិស្សានុសិស្ស ព្រមទាំងចែកប្រាសដុសធ្មេញ ថ្នាំដុសធ្មេញ សម្ភារសិក្សា និងទូរទស្សន៍ នៅសាលាបឋមសិក្សាកំពង់ស្វាយ ខេត្តកំពង់ធំ។
- បានអញ្ជើញនាំយកសម្ភារសិក្សា កង់ និងទូរទស្សន៍ ចែកជូនដល់សិស្សានុសិស្ស នៅសាលាបឋមសិក្សាអាត់ស៊ូ និងសាលាបឋមសិក្សាកូនក្អែក នៅស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ។
- បានអញ្ជើញសួរសុខទុក្ខ **ឯកឧត្តម ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភា និងជាសមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដែលសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន នៅសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានអញ្ជើញជាអធិបតី និងអញ្ជើញចូលរួមក្នុងពិធីនានា នៅរាជធានី និងតាមបណ្តាខេត្ត រួមមាន៖
    - អញ្ជើញចូលរួមក្នុងព្រះរាជពិធីសម្ពោធមហាកុដិសម្តេចព្រះសង្ឃរាជ ជួន ណាត និងវិទ្យាស្ថានស្រាវជ្រាវ និងអភិរក្សសាស្រ្តាស្លឹករឹតខ្មែរ ព្រមទាំងសមិទ្ធផលនានា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** នៅវត្តឧណ្ណាលោម រាជធានីភ្នំពេញ។
    - អញ្ជើញចូលរួមក្នុងពិធីសម្ពោធអគារសិក្សា និងសមិទ្ធផលនានាក្នុងបរិវេណវត្តព្រះឥន្ទសាមគ្គីធម៌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅភូមិត្រពាំងក្រពើ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល។
    - អញ្ជើញជូន និងទទួលដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា បំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
    - តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ** ប្រធានព្រឹទ្ធសភា ថ្លែងសុន្ទរកថាបិទសិក្ខាសាលាស្តីពី ប្រាក់រៀល ប្រព័ន្ធបាគង និងខេអេចឃ្យូអរ (KHQR) និងពិធីអបអរសាទរទិវាប្រាក់រៀល ខួបលើកទី៤៥ នៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ។
    - តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ** ប្រធានព្រឹទ្ធសភា ថ្លែងសុន្ទរកថាបិទក្នុងសិក្ខាសាលាសភាថ្នាក់តំបន់ស្តីពី "បម្រែបម្រួលប្រជាសាស្រ្ត និងជំងឺ

មិនឆ្លង៖ គោលនយោបាយឆ្លើយតបបញ្ហាប្រឈមសម្រាប់ប្រជាជនសកម្ម និងយុវជន” នៅវិមានរដ្ឋសភា។

- អញ្ជើញជាអធិបតីក្នុងវេទិកាផ្សព្វផ្សាយ “វឌ្ឍនភាពនៃការចុះបញ្ជីដីធ្លីបរិយាកាសគ្មានវិវាទ” នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា។
- អញ្ជើញជាអធិបតីក្នុងសិក្ខាសាលាជម្រាបជូនឯកអគ្គរាជ/រដ្ឋទូត និងប្រធានបេសកកម្មការទូតប្រចាំព្រះរាជាណាចក្រកម្ពុជា អំពី “សមិទ្ធផលការទូតសភារបស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៥ នៅក្នុងឆ្នាំ២០២៤”។
- អញ្ជើញជាអធិបតីក្នុង (១) ពិធីក្រុងពាលី និងចុះអនុស្សរណៈសាងសង់អគារសិក្សាចំនួន១ខ្នង មានចំនួន៥បន្ទប់ នៅសាលាបឋមសិក្សាក្រចាប ស្ថិតក្នុងភូមិក្រចាបទី១ ឃុំព្រៃខ្លា ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង និង (២) ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារសិក្សា១ខ្នង មាន៣បន្ទប់ និងសមិទ្ធផលនានា នៅសាលាបឋមសិក្សាមិល ស្ថិតនៅភូមិមិល ឃុំឃ្សឹម ស្រុកស្នួល ខេត្តក្រចេះ។
- អញ្ជើញជាអធិបតីក្នុងពិធីបើកវេទិកាស្តីពី “ពង្រឹងសមត្ថភាពដឹកនាំក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី និងសហគ្រិនជាស្ត្រី រួមទាំងវិស័យឌីជីថល” នៅខេត្តកំពត។
- អញ្ជើញចូលរួមពិធីបុណ្យទន្លេលើកទី៩ ឆ្នាំ២០២៥ ក្រោមប្រធានបទ “គុណតម្លៃនៃទន្លេ៖ ផ្សារភ្ជាប់វប្បធម៌ និងទេសចរណ៍ធម្មជាតិ” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តតាកែវ។
- អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបំពាក់ឋានន្តរសក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផុតលេខ ផ្កាយមាស ៥ នៃកងយោធពលខេមរភូមិន្ទជូន **សម្តេចពិជ័យសេនា ទៀ បាញ់** និង**សម្តេចកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា។
- អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពឯក**ឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត **សម្តេចតេជោ**។
- អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពសាច់ញាតិរបស់ថ្នាក់ដឹកនាំអាជ្ញាធរមូលដ្ឋាន នៅរាជធានីភ្នំពេញ ចំនួន ២កម្មវិធីផ្សេងទៀត។

## ២-សកម្មភាពគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានបើកកិច្ចប្រជុំចំនួន៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖

១- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ សុំដាក់សេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។

២-ពិនិត្យសំណើរបស់រដ្ឋសភា និងពិនិត្យសម្រេចលើសំណើរបស់គណៈកម្មការជំនាញ សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និងសេចក្តីព្រាងច្បាប់ ស្តីពីការចាត់ចែងជា

បណ្តោះអាសន្ននូវវត្ថុចាប់យក ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។

## ៣-សកម្មភាពប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ

ព្រឹទ្ធសភាបានបើកសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និងឯកឧត្តម **អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បី៖

១- ពិនិត្យ និងអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា។

២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការប្រឆាំងការមិនទទួលស្គាល់ឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

៣- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក។

## ៤-ការងារការទូតសភា

ស្ថិតក្នុងបរិបទដែលសភាពការណ៍ពិភពលោកមានការវិវឌ្ឍមិនថមថយ និងកើនឡើងនូវភាពមិនប្រាកដប្រជា បញ្ហាប្រឈម និងហានិភ័យខ្ពស់ ដែលបង្កឡើងដោយរបត់នយោបាយរបស់ប្រទេសមហាអំណាច ការប្រកួតប្រជែងយុទ្ធសាស្ត្រ-ភូមិសាស្ត្រកាន់តែស្រួចស្រាល់ ភាពតានតឹងនៃជម្លោះ និងការរីកសាយនៃសង្គ្រាមក្នុងតំបន់មួយចំនួននៅលើពិភពលោក សកម្មភាពលើកកម្ពស់ការទូតសភាក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី កាន់តែត្រូវបានពង្រីក និងបង្ហាញកាន់តែច្បាស់ពីសារៈសំខាន់នៃតួនាទីជាសារវន្តនៃកិច្ចការនេះ ក្នុងការរួមចំណែកស្តារ រក្សា និងពង្រឹងសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់ និងពិភពលោក។

ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប៉ិនប្រសប់ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សកម្មភាពការទូតសភានៃព្រឹទ្ធសភានីតិកាលទី៥ ត្រូវបានបន្តបង្កើន និងលើកកម្ពស់ក្នុងការរួមចំណែកដល់រាជរដ្ឋាភិបាលក្នុងកិច្ចខិតខំពង្រឹងការងារការទូត តាមរយៈជំនួបសន្ទនា និងការពិភាក្សាជាមួយតួអង្គពាក់ព័ន្ធទាំងអស់ រួមមានថ្នាក់ដឹកនាំបរទេសគ្រប់ជាន់ថ្នាក់ អង្គទូតនៃបណ្តាប្រទេសជាមិត្តរបស់កម្ពុជា ដៃគូអភិវឌ្ឍន៍ ថ្នាក់ដឹកនាំអង្គការអន្តរជាតិ ក៏ដូចជាស្ថាប័នផ្នែកធុរកិច្ច សង្គម និងស្រាវជ្រាវ ដែលទាំងអស់នេះធ្វើឡើងគឺដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាពយូរអង្វែងរបស់កម្ពុជា តំបន់ និងពិភពលោក។

នៅក្នុងបរិបទនេះ គិតពីថ្ងៃទី៦ ខែមករា រហូតដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៥ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងនាមជាប្រមុខរដ្ឋស្តីទី និងក្នុងនាមជាប្រធានព្រឹទ្ធសភា បានទទួលជួបសវនាការ និងពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ ឯកអគ្គរាជ/រដ្ឋទូត និងស្ថាប័ននានា ចំនួន១៤លើក រួមមាន៖

- ព្រះអង្គម្ចាស់ Guillaume Jean Joseph Marie រាជទាយាទ នៃប្រទេសលុចសំបួ ក្នុងឱកាសយាងគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើត សម្តេចតេជោ។

- ឯកឧត្តមបណ្ឌិត **តាន់ស្រី ដាតូ ចូហារិ ប៊ិន អាប់ឌុល** ប្រធានរដ្ឋសភាម៉ាឡេស៊ី។
- លោកជំទាវ **ម៉ាតា ម៉ាគ្រែ** អនុប្រធានទី១នៃរដ្ឋសភាហុងគ្រី។
- ឯកឧត្តម **ជែម កាម៉ាល់ ខាន់** រដ្ឋមន្ត្រីពាណិជ្ជកម្មនៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន។
- ឯកឧត្តម **គីម ជីនព្យូ** អតីតប្រធានរដ្ឋសភាកូរ៉េ និងជាប្រធានក្រុមប្រឹក្សាអង្គការដើម្បីពិភពលោកទាំងអស់គ្នា។
- ឯកឧត្តម **យីន លី** សមាជិកការិយាល័យនយោបាយនៃបក្សកុម្មុយនីស្តចិន និងជាលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិនប្រចាំរដ្ឋធានីប៉េកាំង។
- លោកជំទាវ **ជាវ ឡេ ឈិង** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសិង្ហបុរី។
- ឯកឧត្តម **វ៉ាន់ ឡាល់វ៉ាវណា បារីតលុង** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌា។
- ឯកឧត្តម **អាណាតូលី បូរ៉ូវីក** ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី។
- ឯកឧត្តម **ង្វៀន មិញវូ** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- ឯកឧត្តម **អាលី អាកបារ ណាហ្សារី** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់។
- គណៈប្រតិភូកុងស៊ុលកិត្តិយសប្រចាំកម្ពុជា ដែលដឹកនាំដោយលោកបណ្ឌិត **សាឡា អេសា** កុងស៊ុលកិត្តិយសនៃសាធារណរដ្ឋស៊ីប និងជាព្រឹទ្ធបុរសនៃកុងស៊ុលកិត្តិយសប្រចាំកម្ពុជា។
- លោក **អេឌី ពីរ៉ាជ** អគ្គនាយក និងជានាយកប្រតិបត្តិ ក្រុមហ៊ុន JTI International។
- លោកសាស្ត្រាចារ្យ **តេតស៊ូយ៉ា វ៉ាតាណាបេ** និងគណៈប្រតិភូ វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់កិច្ចការអាស៊ាន និងអាស៊ីបូព៌ា (ERIA)។

ក្នុងឱកាសនៃជំនួបពិភាក្សាការងារនីមួយៗ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា បានផ្លាស់ប្តូរកិច្ចសន្ទនា ពិភាក្សា និងផ្តល់អនុសាសន៍នានា ប្រកបដោយភាពវាងវៃ បត់បែន និងស៊ីជម្រៅ និងតម្កល់ផលប្រយោជន៍ប្រជាជន និងជាតិជាធំ ដោយបានជំរុញការរឹតចំណងទំនាក់ទំនងមិត្តភាព កិច្ចសហប្រតិបត្តិការទ្វេទិសយ៉ាងសកម្ម រឹងមាំ និងទូលំទូលាយ ជាពិសេសជំរុញកិច្ចសហប្រតិបត្តិការលើវិស័យវិនិយោគ ពាណិជ្ជកម្ម ទេសចរណ៍ ការផ្ទេរបច្ចេកវិទ្យា និងនវានុវត្តន៍ ការកៀរគរជំនួយអភិវឌ្ឍន៍ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីរួមចំណែកលើកកម្ពស់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

ជាមួយគ្នានេះ នៅក្នុងស្មារតីរឹតចំណងមិត្តភាព សាមគ្គីភាព និងការលើកស្ទួយកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងបណ្តាប្រទេសជាមិត្ត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូកម្ពុជាបំពេញទស្សនកិច្ចនៅក្រៅប្រទេសដូចជា៖

១. ការអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ពីថ្ងៃទី៦ ដល់ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥ ដោយនៅក្នុងឱកាសនោះ **សម្តេចតេជោ** បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំឡាវ រួមមាន **ឯកឧត្តមបណ្ឌិត សៃស៊ុមផន កុមវិហាន** ប្រធានរដ្ឋសភា **ឯកឧត្តម សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រី និង**ឯកឧត្តម ថងលុន ស៊ីសុលីត** ប្រធានរដ្ឋឡាវ អំពីការធ្វើឱ្យស៊ីជម្រៅនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននីតិប្បញ្ញត្តិ រវាងរដ្ឋនិងរដ្ឋ និងរវាងគណបក្សប្រជាជនកម្ពុជា និងបក្សប្រជាជនបដិវត្តន៍ឡាវ ដើម្បីផ្តល់ប្រយោជន៍កាន់តែជាក់ស្តែង និងសម្បូរបែបសម្រាប់ប្រជាជន និងប្រទេសទាំងពីរ។

២. ការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលបក្សទ្វេភាគី កម្ពុជា-វៀតណាម និងត្រីភាគី កម្ពុជា-ឡាវ-វៀតណាម នៅទីក្រុងហូជីមិញ សាធារណរដ្ឋសង្គមនិយមវៀតណាម ពីថ្ងៃទី២១ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៥ ដោយក្នុងឱកាសនោះ **សម្តេចតេជោ** បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំវៀតណាម និងឡាវ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ រួមមានកិច្ចការការទូតសភាផងដែរ។

**ឯកឧត្តម អ៊ិច ប៊ូរិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា បានអញ្ជើញទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ និងចូលរួមពិធីផ្សេងៗ រួមមាន៖

- ទទួលជួបពិភាក្សាការងារជាមួយ **ឯកឧត្តម អាណាតូលី បូរ៉ូវីក** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា ចំនួន ២ដង។
- ទទួលពិសាអាហារថ្ងៃត្រង់ការងារជាមួយ **លោក ដាមីយ៉េន សេសស៊ីឡាំង** អគ្គលេខាធិការនៃសភាប្រើភាសាបារាំង ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នសភា និងសភាប្រើភាសាបារាំង។
- ទទួលរៀបចំអាហារពេលព្រឹកការងារជាមួយ **លោកជំទាវ ប្រៃហ្គេត អិល វ៉ែឃើ** ភារធារីស្តីទីនៃស្ថានទូតអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា។
- ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូគណៈកម្មការសម្រាប់ភាពជាអ្នកជិតខាងល្អ មិត្តភាព និងកិច្ចសហប្រតិបត្តិការ (GNFCC) នៃអង្គការសហប្រតិបត្តិការសៀងហៃ ដឹកនាំដោយ **លោកស្រី ឌុយ លី** អនុប្រធានគណៈកម្មការ។
- អញ្ជើញចូលរួមពិធីជប់លៀងនៅនិវេសនដ្ឋានរបស់ឯកឧត្តមឯកអគ្គរដ្ឋទូតរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា និងទទួលរៀបចំអាហារថ្ងៃត្រង់ជូនឯកឧត្តមឯកអគ្គរដ្ឋទូតរុស្ស៊ី នៅរាជធានីភ្នំពេញ។

ចំពោះការបំពេញការងារនៅក្រៅប្រទេស **ឯកឧត្តម អ៊ិច ប៊ូរិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួម៖

១. ទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ដោយក្នុងឱកាសនោះ **ឯកឧត្តម អនុប្រធានទី១** បានជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ**ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម **ឯកឧត្តម ឡេ ហាយជុង** ប្រធានគណៈទាក់ទងបរទេសនៃបក្សកុម្មុយនីស្តវៀតណាម **ឯកឧត្តម ង្វៀន ជុងឌុង** អនុប្រធានគណៈកម្មាធិការប្រជាជនទីក្រុងហាណូយ និង**ឯកឧត្តម វ៉ូ ដាយថាំង** សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាលេខាគណៈកម្មាធិការបក្សខេត្តក្វាងនិញ។ ក្នុងអំឡុងពេលនោះ **ឯកឧត្តម អនុប្រធានទី១** ក៏បានអញ្ជើញធ្វើទស្សនកិច្ចសិក្សានៅរោងចក្រកែច្នៃសំរាមជាថាមពល "សុកសឺន" នៅរដ្ឋធានីហាណូយ។

២. កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង (APF) និងកិច្ចប្រជុំពាក់ព័ន្ធក្រោមមូលបទស្តីពី "តួនាទីរបស់សភាប្រើភាសាបារាំង ចំពោះការប្រឈមមុខនឹងការផ្លាស់ប្តូរសណ្តាប់ធ្នាប់ពិភពលោក" នៅខេត្តកាន់ថឺ សាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥ ដោយក្នុងឱកាសនោះ អង្គប្រជុំបានអនុម័តជា

ឯកច្ចន្ទជូន **ឯកឧត្តម អនុប្រធានទី១** ជាអនុប្រធាននៃសភាប្រេីកាសាបារាំង។ ជាមួយគ្នានេះ **ឯកឧត្តម អនុប្រធានទី១** បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ជិន ថាញ់មិន** សមាជិកគណៈលេខាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និងជាប្រធានរដ្ឋសភាវៀតណាម និង **ឯកឧត្តម** Hilarion ÉTONG ប្រធានសភាប្រេីកាសាបារាំង។

៣. មហាសន្និបាតសហភាពអន្តរសភាលើកទី១៥០ (IPU-150) នៅទីក្រុងតាស្កិន ប្រទេសអ៊ូសបេគីស្ថាន ចាប់ពីថ្ងៃទី០៣ ដល់ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥ ដោយក្នុងឱកាសនោះ **ឯកឧត្តម អនុប្រធានទី១** បានអញ្ជើញចូលរួមថ្លែងសុន្ទរកថាក្នុងកិច្ចពិភាក្សាទូទៅនៃមហាសន្និបាតសហភាពអន្តរសភា ក្រោមប្រធានបទ "**សកម្មភាពសភា ដើម្បីយុត្តិធម៌ និងការអភិវឌ្ឍសង្គម**"។ ក្រៅពីនេះ ក្នុងនាមជាប្រធានគណៈប្រតិភូកម្ពុជា **ឯកឧត្តម អនុប្រធានទី១** បានអញ្ជើញចូលរួមកិច្ចប្រជុំពាក់ព័ន្ធសំខាន់ៗ រួមមាន៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលមហាសន្និបាតសហភាពអន្តរសភា និងសន្និសីទលើកទី៤ នៃបណ្តាញសភាក្រុមប្រទេសមិនចូលបក្សសម្ព័ន្ធ ព្រមទាំងបានជួបទ្វេភាគីជាមួយលោកជំទាវ ប្រធាន ព្រឹទ្ធសភាអ៊ូសបេគីស្ថាន ដែលជាម្ចាស់ផ្ទះ និងប្រធានប្រតិភូសភានៃប្រទេសមួយចំនួនទៀត។

**ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ ព្រឹទ្ធសភា** បានអញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវអន្តរជាតិ និងចូលរួមពិធីផ្លូវការ មានជាអាទិ៍៖

- ក្រុមហ៊ុនវិនិយោគជប៉ុន អំពីការកសាងមជ្ឈមណ្ឌលអាហារូបត្ថម្ភ និងទារកដ្ឋាន។
- ក្រុមហ៊ុនវិនិយោគជប៉ុន អំពីការកសាងមជ្ឈមណ្ឌលស្រាវជ្រាវចំណីអាហារ និងការបណ្តុះបណ្តាល។
- **លោក អាស៊ូស៊ី ណារូស** អភិបាលក្រុង Kota ប្រទេសជប៉ុន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារទាក់ទងនឹងការពង្រឹងទំនាក់ទំនងការទូត កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អប់រំ សុខាភិបាល និងការផ្លាស់ប្តូរប្រជាជន និងប្រជាជន។
- ជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងជំនួបពិភាក្សាការងាររវាងគណៈប្រតិភូព្រឹទ្ធសភា ដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ម៉ុង ឬទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ជាមួយនឹងគណៈប្រតិភូកូរ៉េនៃវិទ្យាស្ថានបច្ចេកវិទ្យា និងវិទ្យាសាស្ត្រ (DIST) ដឹកនាំដោយ **លោក លី ជូន ហ៊ីយ៉ាន់** ប្រធាននាយកដ្ឋានក្រុមហ៊ុន DIST IUC ដើម្បីស្វែងរកដៃគូអភិវឌ្ឍន៍ទាក់ទងនឹងវិស័យកសិកម្ម (កម្មវិធី SMART FARM)។
- អញ្ជើញចូលរួមកម្មវិធីទិវាបុណ្យជាតិអូស្ត្រាលី នៅស្ថានទូតអូស្ត្រាលី។
- អញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍ជូនអង្គទូត ដែលរៀបចំដោយគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃព្រឹទ្ធសភា។
- អញ្ជើញចូលរួមកម្មវិធី Charity Gala Dinner។

ជាមួយគ្នានេះ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធឯកឧត្តមនាយឧត្តមសេនីយ៍ ខាំតៃ ស៊ីផាន់ដុន អតីតប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលត្រូវជាឪពុកបង្កើតរបស់ឯកឧត្តម សនសៃ ស៊ីផាន់ដុន នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៥។

ដោយឡែក ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា បានរួមចំណែកបំពេញការងារសហប្រតិបត្តិការអន្តរជាតិយ៉ាងសកម្ម និងផុសផុល ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ដើម្បីរួមចំណែកលើកស្ទួយ និងពង្រឹងការអនុវត្តវិស័យការទូតសភា ដោយបានអញ្ជើញចូលរួមកិច្ចប្រជុំ និងវេទិកាអន្តរសភានានា ចំនួន៦លើក រួមមាន៖

- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ និងមហាសន្និបាតលើកទី១៥នៃសភាតំបន់អាស៊ី (APA) នៅទីក្រុងបាគូ ប្រទេសអាស៊ែបៃហ្សង់។
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃបណ្ដាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា ដើម្បីពិភាក្សាអំពីការផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍សម្រាប់ឆ្នាំ២០២៥ តាមប្រព័ន្ធនិម្មិត (Video Conference)។
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្ដីពី កិច្ចការនយោបាយនៃសភាតំបន់អាស៊ី (APA) នៅទីក្រុងបាកដាដ ប្រទេសអ៊ីរ៉ាក់។
- ចូលរួមកិច្ចប្រជុំគណៈកម្មការកិច្ចការសភានៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។
- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រើភាសាបារាំង (APF) នៅខេត្តកាន់ថឺ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
- ចូលរួមទស្សនកិច្ចសិក្សាស្វែងយល់ពីរោងចក្រផលិតជីសរីរាង្គ និងទស្សនកិច្ចតំបន់កសិកម្ម កសិ-ឧស្សាហកម្ម នៅខេត្តសានដុង ប្រទេសចិន។

ក្រៅពីការបំពេញបេសកកម្មនៅក្រៅប្រទេស គណៈកម្មការនានានៃព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិ ក្នុងគោលបំណងពង្រឹងវិស័យការទូតសភា ពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗ ចំនួន១២លើក។

សរុបមក សកម្មភាព និងកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការងារការទូតសភាយ៉ាងសកម្ម ទូលំទូលាយ និងផុលផុស ពីសំណាក់ប្រធាន អនុប្រធាន សមាជិក សមាជិកា គណៈកម្មការជំនាញ និងការផ្ដល់សេវាដ៏មានប្រសិទ្ធភាពពីអគ្គលេខាធិការដ្ឋាន ក្រោមការដឹកនាំរបស់ **សម្ដេចតេជោ ប្រធានព្រឹទ្ធសភា** ប្រកបដោយទស្សនវិស័យវែងឆ្ងាយ ពិតជាបានរួមចំណែកដ៏ធំធេង ក្នុងការងារការទូតជាតិទាំងមូល ដោយធានាបាននូវការតម្កល់ប្រយោជន៍ដ៏ឧត្តុង្គឧត្តមជូនជាតិ និងមាតុភូមិកម្ពុជា ហើយក៏ជាភាគទានមួយដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាព ក្នុងតំបន់ និងពិភពលោក។

## ៥- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ បានយកចិត្តទុកដាក់អនុវត្តមុខងារតំណាងយ៉ាងខ្ជាប់ខ្ជួន ដើម្បីផ្សារភ្ជាប់ការងាររបស់ខ្លួនទៅនឹងការងារនៅថ្នាក់ក្រោមជាតិ ដោយសម្រេចបានលទ្ធផលសំខាន់ៗ ដូចតទៅ៖

**- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១៖**

- បានធ្វើពិធីសំណេះសំណាល ចំនួន៣លើក ជាមួយក្រុមប្រឹក្សាសង្កាត់ ស្មៀន និងនាយប៉ុស្ដិ៍នគរបាលរដ្ឋបាលទាំង១៨ខណ្ឌ នៃរាជធានីភ្នំពេញ ដើម្បីឈ្វេងយល់អំពីបញ្ហាប្រឈម និងសំណូមពរក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការងារ

អត្តសញ្ញាណកម្ម និងអត្រានុកូលដ្ឋាន ការងារលទ្ធកម្មតាមមូលដ្ឋាន ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបច្ចេកទេសជូនដល់យុវជនមកពីគ្រួសារក្រីក្រនៅរាជធានីភ្នំពេញ និងការងារ ប.ស.ស ដោយមានសមាសភាពចូលរួមសរុបចំនួន៥៧៧នាក់ ក្នុងនោះក្រុមប្រឹក្សាសង្កាត់ ចំនួន៣១៥នាក់។

- បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តអង្គការសង្គ្រោះវេជ្ជសាស្ត្រអន្តរជាតិ (IMR) ប្រចាំកម្ពុជារបស់សហរដ្ឋអាមេរិក ព្រមទាំងសម្ព័ន្ធគ្រូពេទ្យសហភាពសហព័ន្ធយុវជនកម្ពុជា (ស.គ.ស.ស.យ.ក) និងសមាគមបេសកកម្មមនុស្សធម៌ (AMH) នៅកម្ពុជារបស់ប្រទេសបារាំង ចុះទៅពិនិត្យ និងព្យាបាលជំងឺទូទៅមិនយកកម្រៃ ជូនប្រជាពលរដ្ឋចំនួន៥លើក នៅខណ្ឌមានជ័យ ច្បារអំពៅ កំបូល ដង្កោ និងខណ្ឌព្រែកព្នៅ សរុបចំនួន៧៦៥នាក់។

- **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២៖**

- បានរៀបចំកម្មវិធីសំណេះសំណាលចំនួន១៩លើក ដោយឡែកៗពីគ្នា នៅតាមសាលាឃុំ-សង្កាត់នីមួយៗ នៃឃុំ-សង្កាត់ទាំង៦៤ ក្នុងស្រុក-ក្រុងទាំង៧ នៅទូទាំងខេត្តត្បូងឃ្មុំ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព ដោយមានសមាសភាពចូលរួមសរុបចំនួន ៩៤៤នាក់ ដែលក្នុងនោះមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៥៣៦នាក់។ គោលដៅនៃការជួបសំណេះសំណាល គឺដើម្បីពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការផ្តល់សេវាសាធារណៈ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ និងការអភិវឌ្ឍមូលដ្ឋាន។
- បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា (AMH) របស់ប្រទេសបារាំង ចុះពិនិត្យព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋ នៅក្រុងសួង និងស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ សរុប ចំនួន៣០០នាក់ ព្រមទាំងបានសម្របសម្រួលជាមួយតំណាងក្រុមហ៊ុន Laboratoire Bioderma ប្រទេសបារាំង ដើម្បីត្រៀមរៀបចំកម្មវិធីចុះពិនិត្យនិងព្យាបាលជំងឺជូនប្រជាជន ដោយឥតគិតថ្លៃ ដោយក្រុមវេជ្ជបណ្ឌិតស្ម័គ្រចិត្តបារាំង នៅតាមបណ្តាឃុំជាប់ព្រំដែនវៀតណាម នៃខេត្តត្បូងឃ្មុំ។
- បានជួសជុលផ្តល់ជូនតាមសំណើរបស់ប្រជាពលរដ្ឋរស់នៅក្នុងឃុំជាលា ខេត្តកំពង់ចាម នូវផ្លូវលំ១ខ្សែប្រវែង ២,៧៥០ម៉ែត្រ ទទឹង ៨ម៉ែត្រ ដោយតភ្ជាប់ចាប់ពីចំណុចភូមិភ្នំដិលដល់ភូមិតាំងក្រាំង និងដល់ភូមិតាងីល។ ជាមួយគ្នានេះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងក្រុមទីប្រឹក្សាឯកឧត្តមអនុប្រធានទី១ ព្រឹទ្ធសភា កំពុងបន្តតាមដានដំណើរការជួសជុលសាលាធម្មសភា ស្ថិតក្នុងសីមាវត្តជ្រៃបិតមាស ក្រុងសួង ខេត្តត្បូងឃ្មុំ និងដំណើរការសាងសង់ព្រះវិហារ ស្ថិតក្នុងសីមាវត្តនិគ្រោធធម្មាសុខារាម (ហៅវត្តអន្លង់ជ្រៃ) ឃុំច្បារអំពៅ ស្រុកបាធាយ ខេត្តកំពង់ចាម។

- **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣៖** បានធ្វើពិធីសំណេះសំណាល ចំនួន១១លើក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រធានមណ្ឌលសុខភាព នៅទូទាំងខេត្តកណ្តាល (១៣ក្រុង ស្រុក) ដើម្បីឈ្វេងយល់ពីការអភិវឌ្ឍមូលដ្ឋាន ការអនុវត្ត

មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និង ធ្វើបទបង្ហាញទាក់ទងនឹងការផ្តល់សេវាសាធារណៈ (ការចុះបញ្ជីអត្រានុកូលដ្ឋាន) ការប្រើប្រាស់ប័ណ្ណបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ព្រមទាំងបានពិភាក្សាអំពីបញ្ហាប្រឈម និងសំណូមពរ ដោយមានសមាសភាពចូលរួម សរុបចំនួន១៤៣៥នាក់ ក្នុងនោះមានក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន៩១២នាក់ ស្មៀន ចំនួន១២៧នាក់ នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ចំនួន១២៧នាក់ មន្ត្រី ប.ស.ស ចំនួន៨នាក់ និងប្រធានមណ្ឌលសុខភាព ចំនួន១០២នាក់ និងចំណាយថវិកាសរុប ចំនួន១២៥.៦៧០.០០០រៀល។

- **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤៖**
  - បានធ្វើពិធីសំណេះសំណាលចំនួន២លើក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ក្នុងខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន ដើម្បីឈ្វេងយល់ពីការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត តួនាទី ភារកិច្ចក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងអភិបាលកិច្ចល្អរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការផ្តល់សេវាសាធារណៈ ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការផ្លាស់ចេញ-ចូល ការងារអត្រានុកូលដ្ឋាន ការកែអក្ខរាវិរុទ្ធ និងទិន្នន័យនៃអត្រានុកូលដ្ឋាន ការអនុវត្តមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ បញ្ហាប្រឈមនិងសំណូមពរ ដោយមានសមាសភាពចូលរួមសរុប ចំនួន៤៧៨នាក់ ក្នុងនោះមានក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន២០៤នាក់។
  - បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តនៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា (AMH) របស់ប្រទេសបារាំង ចុះទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅស្រុកឯកភ្នំ ខេត្តបាត់ដំបង សរុបចំនួន២១៤នាក់។

- **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥៖**
  - បានធ្វើពិធីសំណេះសំណាល ចំនួន៥លើក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅស្រុកអង្គបុរី ស្រុកព្រៃកប្បាស ខេត្តតាកែវ និងស្រុកកំពង់ត្រាច ស្រុកបន្ទាយមាស ខេត្តកំពត និងខេត្តកែប ដើម្បីពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការផ្តល់សេវាសាធារណៈ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការអភិវឌ្ឍមូលដ្ឋាន បញ្ហាប្រឈម និងសំណូមពរ ដោយមានសមាសភាពចូលរួមសរុប ចំនួន៤៥៥នាក់ ក្នុងនោះមានក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន១២៧នាក់។
  - បានចុះពិនិត្យ និងស្តារស្រះទឹក ចំនួន៥កន្លែង ក្នុងខេត្តកំពត និងចូលរួមបដិភាគថវិកា ចំនួន៣.៥០០.០០០រៀល ដើម្បីជីកស្រះទឹកថ្មី១កន្លែង ទំហំ១០០ម៉ែត្រ x ២០ម៉ែត្រ x ៤ម៉ែត្រ ស្ថិតនៅក្នុងវត្តមុនីសុខារាម ភូមិកំពង់ចិន ឃុំស្ទឹងកែវ ស្រុកទឹកឈូ ខេត្តកំពត។

- **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦៖**
  - បានធ្វើពិធីសំណេះសំណាលចំនួន១៧លើក ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលចំនួន១១ក្រុង ស្រុក នៃខេត្តព្រៃវែង និងចំនួន៦ក្រុង ស្រុក នៃខេត្តស្វាយរៀង ដើម្បីឈ្វេងយល់ពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

វឌ្ឍនភាពការងារ ការផ្ដល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន បញ្ហាប្រឈម និងសំណូមពរ ដោយមានសមាសភាពចូលរួមសរុបចំនួន៥២៣នាក់ ក្នុងនោះមានក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន៣៦៨នាក់។

- បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា (AMH)របស់ប្រទេសបារាំង ចុះទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅស្រុកបាភ្នំ ខេត្តព្រៃវែង សរុបចំនួន៣៣០នាក់។

**- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧៖**

- បានធ្វើពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលទាំងអស់ក្នុងខេត្តកំពង់ឆ្នាំង ដើម្បីឈ្វេងយល់ពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការផ្ដល់សេវាសាធារណៈ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការអភិវឌ្ឍមូលដ្ឋាន បញ្ហាប្រឈម និងសំណូមពរ ដោយមានសមាសភាពចូលរួមសរុប ចំនួន៦៥៦នាក់ ក្នុងនោះមានក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន៤២៧នាក់។
- បានជីកស្រះទឹក ទំហំ១១០ម៉ែត្រx២២០ម៉ែត្រx១០ម៉ែត្រ ធ្វើផ្លូវលំ២ខ្សែ (ក្រាលក្រួសក្រហមមួយខ្សែប្រវែង៣.២០០ម៉ែត្រ និងផ្លូវក្រាលកម្ទេចថ្មមួយខ្សែប្រវែង១.១០០ម៉ែត្រ) និងពង្រីកផ្លូវពី៦ម៉ែត្រ ទៅ១០ម៉ែត្រ ប្រវែង៣.២០០ម៉ែត្រ ព្រមទាំងបានដាក់លូ ស្ថិតនៅឃុំសែនជ័យ ស្រុកសំពៅងទង ខេត្តកំពង់ស្ពឺ ក្រោមការឧបត្ថម្ភថវិការបស់**ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** រួមជាមួយសមាជិក សមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧។

**- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨៖** បានធ្វើពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងខេត្តស្ទឹងត្រែង ដើម្បីឈ្វេងយល់ពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការផ្ដល់សេវាសាធារណៈ ការអភិវឌ្ឍឃុំ សង្កាត់ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការអភិវឌ្ឍមូលដ្ឋាន បញ្ហាប្រឈម និងសំណូមពរ ដោយមានសមាសភាពចូលរួមសរុប ចំនួន១៨២នាក់ ក្នុងនោះមានក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន១៥៣នាក់។

**- សកម្មភាពការងាររួមរបស់សមាជិក សមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨៖** សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅប្រាស្រ័យទាក់ទង និងសួរសុខទុក្ខប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិភាគរបស់ខ្លួន ចូលរួមក្នុងកម្មវិធីនានា ការអភិវឌ្ឍមូលដ្ឋាន ការងារសង្គមកិច្ច ការងារមនុស្សធម៌ និងបានជួយអន្តរាគមន៍ទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីដោះស្រាយសំណូមពរ សំណើផ្សេងៗជូនប្រជាពលរដ្ឋ **សរុបចំនួន៣៨៤លើក។**

ជាការសន្និដ្ឋានរួម ការចុះបំពេញតួនាទីដ៏សកម្មនេះ បានឆ្លុះបញ្ចាំងមិនត្រឹមតែអំពីការតាមដាន និងពិនិត្យមើលដំណើរការការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ សំដៅជំរុញឱ្យមានការអភិវឌ្ឍតាមគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការផ្សារភ្ជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាម្ចាស់ឆ្នោត ដើម្បីឈ្វេងយល់អំពីភាពជាក់ស្តែងនៃសេចក្តីត្រូវការចាំបាច់នានា ក្នុងន័យស្វែងរកដំណោះស្រាយ ដើម្បីពង្រឹង និងលើកកម្ពស់ការអភិវឌ្ឍនៅក្នុងមណ្ឌលភូមិភាគរបស់ខ្លួន។

## ៦-ក្រុមសមាជិកាព្រឹទ្ធសភា

ក្នុងចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣នេះ ក្រុមសមាជិកាព្រឹទ្ធសភា បានបន្តចុះជួបសំណេះសំណាលជាមួយក្រុមសមាជិកា ព្រមទាំងបានចូលរួមចំណែកធ្វើការងារសង្គមកិច្ច នៅតាមមូលដ្ឋាននានា ដោយមានសកម្មភាពដូចជា៖

- បានធ្វើវេទិកាស្តីពី ការពង្រឹងសមត្ថភាពដឹកនាំក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី និងសហគ្រិនស្ត្រី រួមទាំងវិស័យឌីជីថល នៅខេត្តកំពត ដើម្បីបង្កើនសមត្ថភាពដឹកនាំ គ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី និងសហគ្រិនស្ត្រី ក្នុងការប្រកបមុខរបរអាជីវកម្ម ការគ្រប់គ្រងចំណូលចំណាយ ការភ្ជាប់បណ្តាញអាជីវកម្មខ្នាតមីក្រូ ការយល់ដឹងពីប្រព័ន្ធបច្ចេកវិទ្យាឌីជីថល បញ្ហាប្រឈម និងសំណូមពរ ដោយមានសមាសភាពចូលរួម សរុបចំនួន៣១៦នាក់ ក្នុងនោះក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ចំនួន១៩២នាក់ អាជីវករ និងសហគ្រិនស្ត្រី ចំនួន១០៥នាក់ មកពីខេត្តកំពត តាកែវ និងខេត្តកែប។
- បានជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកធុងចម្រោះទឹកស្អាត ក្រមា និងថវិកា ចែកជូនប្រជាពលរដ្ឋ ចំនួន៨០០គ្រួសារ នៅស្រុកតាំងគោក ស្រុកសណ្តាន់ និងស្រុកប្រាសាទសំបូរ ក្នុងខេត្តកំពង់ធំ។
- សមាជិកាព្រឹទ្ធសភាបានចុះទៅប្រាស្រ័យទាក់ទង និងសួរសុខទុក្ខប្រជាពលរដ្ឋ និងអាជ្ញាធរដែនដីក្នុងភូមិភាគនានា ចូលរួមក្នុងកម្មវិធីផ្សេងៗ ការអភិវឌ្ឍមូលដ្ឋាន ការងារសង្គមកិច្ច និងការងារមនុស្សធម៌ សរុបចំនួន២៩លើក។

## II-របាយការណ៍តាមទិស័យរបស់គណៈកម្មការព្រឹទ្ធសភា

នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣នេះដែរ គណៈកម្មការនានារបស់ព្រឹទ្ធសភា បានយកចិត្តទុកដាក់បំពេញការងារយ៉ាងសកម្ម ដោយបានជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ននានា និងការចុះតាមបណ្តាខេត្ត រាជធានី ដើម្បីតាមដានមើលវឌ្ឍនភាពនៃការអនុវត្តច្បាប់ និងគោលនយោបាយនានាស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល មានជាអាទិ៍៖

- **គណៈកម្មការទី១**
    - បានចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការងាររបស់ខេត្ត ការអនុវត្តច្បាប់ ការគោរពសិទ្ធិមនុស្ស ការគោរពសិទ្ធិជនជាតិដើមភាគតិច ស្ថានភាព និងការអនុវត្តសិទ្ធិជនជាប់ឃុំ ការផ្តល់សេវាសាធារណៈ ការដោះស្រាយពាក្យបណ្តឹងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ បញ្ហាប្រឈម និងសំណូមពរ នៅខេត្តព្រះវិហារ ឧត្តរមានជ័យ និងខេត្តសៀមរាប ព្រមទាំងបានទៅទស្សនកិច្ច នៅប្រាសាទព្រះវិហារ។
    - បានជួបពិភាក្សាការងារជាមួយមជ្ឈមណ្ឌលសភាអាស៊ី និងអង្គការដៃគូនានា ចំនួន២លើក នៅរាជធានីភ្នំពេញ ដើម្បីឈ្វេងយល់ពីកម្មវិធី គម្រោងបេសកកម្ម និងកិច្ចសហប្រតិបត្តិការការងារលើវិស័យសិទ្ធិមនុស្ស ពិសេសផ្តោតលើសិទ្ធិជនជាតិដើមភាគតិច។
    - បានទទួលពាក្យបណ្តឹង ចំនួន៣១បណ្តឹង បានបញ្ជូនពាក្យបណ្តឹងទៅក្រសួង ស្ថាប័ន ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន និងអាជ្ញាធរខេត្តពាក់ព័ន្ធ ចំនួន១៩បណ្តឹង កំពុងពិនិត្យសិក្សាចំនួន១២បណ្តឹង តម្កល់ទុកមិនចាត់ការចំនួន៧បណ្តឹង ផ្តល់ព័ត៌មាន

ទៅម្ចាស់បណ្ដឹង ចំនួន២៥បណ្ដឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន៥បណ្ដឹង និងទទួលឯកសារពីក្រសួង ស្ថាប័នពាក់ព័ន្ធ ចម្លងជូនមកគណៈកម្មការ ចំនួន១៨បណ្ដឹង។

- **គណៈកម្មការទី២**
  - បានជួបពិភាក្សាការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ជាមួយធនាគារជាតិនៃកម្ពុជា នៅស្នាក់ទីការកណ្ដាលធនាគារជាតិនៃកម្ពុជា រាជធានីភ្នំពេញ។
  - បានចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់ពីវិស័យជាសមត្ថកិច្ចដោយផ្ដោតលើការអនុវត្តថវិកាថ្នាក់ក្រោមជាតិ បញ្ហាប្រឈមនៃការអនុវត្តថវិកាសមិទ្ធកម្មរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ការប្រមូលចំណូលពន្ធដារ ពន្ធគយ និងរដ្ឋាករ នីតិវិធីសវនកម្ម ស្ថានភាពសាខាធនាគារជាតិ នៅខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។
  - បានចុះទស្សនកិច្ចនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងតំបន់សេដ្ឋកិច្ចពិសេសរ៉ូយ៉ាល់គ្រុបប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។
- **គណៈកម្មការទី៣**
  - បានជួបពិភាក្សាការងារជាមួយក្រសួងធនធានទឹក និងឧតុនិយម ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈមឆ្នាំ២០២៤ និងចក្ខុវិស័យរបស់ក្រសួងឆ្នាំ២០២៥។
  - បានចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការងាររបស់ខេត្ត ការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តព្រះសីហនុ។
- **គណៈកម្មការទី៤**
  - បានជួបពិភាក្សាការងារជាមួយក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យរបស់ក្រសួង។
  - បានចុះបំពេញបេសកកម្ម ដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការរបស់អភិបាលនៃគណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទ និងមន្ទីរពាក់ព័ន្ធនៅខេត្តព្រះវិហារ។
- **គណៈកម្មការទី៥៖** បានចុះបំពេញបេសកកម្មដើម្បីឈ្វេងយល់ពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ច្បាប់សារព័ត៌មាន ការផ្សព្វផ្សាយព័ត៌មាន ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ នីតិវិធី និងបែបបទរដ្ឋបាល និងការអភិវឌ្ឍលើវិស័យនានា នៅច្រកទ្វារអន្តរជាតិកំពង់ផែស្វយ័ត និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ និងមជ្ឈមណ្ឌលភស្តុភារកម្មកំពង់ផែពហុបំណង ក្រុមហ៊ុនកំពតឡូជីស្ទីកអេនផត ឯ.ក និងច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក នៅខេត្តកំពត។
- **គណៈកម្មការទី៦**
  - បានចុះបេសកកម្ម ដើម្បីជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ នៅតាមមូលដ្ឋានអំពីការពង្រឹងប្រសិទ្ធភាពក្នុងការផ្ដល់សេវាសាធារណៈ ការចុះបញ្ជីកំណើត ការចុះបញ្ជីមរណភាព

និងការចុះបញ្ជីអាពាហ៍ពិពាហ៍ជូនប្រជាពលរដ្ឋ នៅស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដោយមានអ្នកចូលរួម ចំនួន១៥០នាក់ និងបានរៀបចំសម្ភារ ឯកសារ ព្រមទាំងបានឧបត្ថម្ភថវិកាក្នុងម្នាក់ៗ ចំនួន៤០,០០០រៀល។

- បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត ដោយផ្តោតសំខាន់ទៅលើស្ថានភាពការអភិវឌ្ឍរបស់ខេត្ត និងការអនុវត្តច្បាប់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ នៅខេត្តស្វាយរៀង។
- បានជួបពិភាក្សាការងារជាមួយសាលាដំបូង និងអយ្យការអមសាលាដំបូង ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់ក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ នៅខេត្តស្វាយរៀង និងរាជធានីភ្នំពេញ។

- **គណៈកម្មការទី៧**
  - បានជួបពិភាក្សាការងារជាមួយក្រសួងទេសចរណ៍ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការដោះស្រាយ និងចក្ខុវិស័យរបស់ក្រសួង។
  - បានចុះបំពេញបេសកកម្មដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការដោះស្រាយ និងចក្ខុវិស័យ ពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តមណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង ព្រមទាំងបានធ្វើទស្សនកិច្ច និងនាំយកគ្រឿងសក្ការៈបូជា បួងសួងលោកតាទេព រមណីយដ្ឋានភ្នំដោះក្រមុំ ព្រះអង្គចូលនិពាន្ទ ព្រះអង្គធំប្រាសាទព្រះគោ បឹងយក្សឡោម និងបានយកទេយ្យទាន បច្ច័យកសាង បច្ច័យប្រគេនព្រះសង្ឃ ជូនតាជី និងយាយជី នៅវត្តឥសានរតនារាម ដើម្បីបួងសួងសុំសេចក្តីសុខ សេចក្តីចម្រើន ជូនដល់ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋខ្មែរ។

- **គណៈកម្មការទី៨**
  - បានចុះបំពេញបេសកកម្មដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានអំពីវឌ្ឍនភាព បញ្ហាប្រឈម និងសំណូមពរ ក្នុងការអនុវត្តច្បាប់ ការផ្សព្វផ្សាយច្បាប់ គោលនយោបាយ ការអនុវត្តតួនាទី ភារកិច្ចរបស់រដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង។
  - បានធ្វើទស្សនកិច្ច និងនាំយកសម្ភារប្រើប្រាស់ គ្រឿងឧបភោគ បរិភោគ ថវិកាឧបត្ថម្ភ សម្រាប់ចូលរួមសាងសង់តំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្មX16 នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ កងកម្លាំងការពារព្រំដែន កងកម្លាំងនគរបាលអន្តោប្រវេសន៍ ចំណុចបង្គោលព្រំដែនលេខ៦៥ ច្រកទ្វារព្រំដែនទ្វេភាគីឡាប៉ាខេ (ព្រំដែនកម្ពុជា-វៀតណាម) នៅស្រុកកែវសីមា ខេត្តមណ្ឌលគិរី បង្គោលព្រំដែនលេខ៣០ ច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ (ព្រំដែនកម្ពុជា-វៀតណាម) នៅស្រុកអូរយ៉ាដាវ ខេត្តរតនគិរី បង្គោលព្រំដែនលេខ០៣៤ និងលេខ០២៤/១ ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល (ព្រំដែនកម្ពុជា-ឡាវ) នៅស្រុកអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ព្រមទាំងបានជួបសំណេះសំណាល និងឧបត្ថម្ភថវិកាជូនលោកគ្រូ អ្នកគ្រូ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី បុគ្គលិកមណ្ឌលសុខភាពលំផាត់ ខេត្តរតនគិរី ក្រុមប្រឹក្សាសង្កាត់ អ្នកគ្រប់គ្រងសមាគម

មនុស្សចាស់ និងជនចាស់ជរា នៅសាលាសង្កាត់សាមគ្គី ខេត្តស្ទឹងត្រែង សរុបថវិកាចំនួន១៨.៣០០.០០០រៀល។

- **គណៈកម្មការទី៩**
  - បានជួបពិភាក្សាការងារជាមួយក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងពាណិជ្ជកម្ម និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីឈ្វេងយល់និងប្រមូលព័ត៌មានអំពីវឌ្ឍនភាព បញ្ហាប្រឈម ទិសដៅ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងនីមួយៗ។
  - បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្តស្ទឹងត្រែង និងខេត្តកំពង់ស្ពឺ ព្រមទាំងបានធ្វើទស្សនកិច្ចសិក្សាឈ្វេងយល់ អំពីដំណើរការប្រតិបត្តិទំនប់វារីអគ្គិសនីសេសានក្រោម២ នៅខេត្តស្ទឹងត្រែង និងស្ថានីយផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ នៅខេត្តកំពង់ស្ពឺ។

- **គណៈកម្មការទី១០**
  - បានជួបពិភាក្សាការងារជាមួយអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។
  - បានចុះបំពេញបេសកកម្មដើម្បីឈ្វេងយល់អំពីប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ នៅខេត្តតាកែវ និងខេត្តព្រៃវែង។

តាមរយៈការឆ្លុះបញ្ចាំងពីជំនួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ននានា និងដំណើរបេសកកម្មនៅមូលដ្ឋាន គណៈកម្មការនានាព្រឹទ្ធសភាសូមវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ដែលមានការរីកចម្រើនលើគ្រប់វិស័យ និងរក្សាបាននូវសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមរឹងមាំ ព្រមជាមួយនឹងការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ និងជីវភាពរបស់ប្រជាជន។

ជារួម រាជរដ្ឋាភិបាលបានអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ រួមទាំងកម្មវិធីគោលនយោបាយជាអាទិភាពសំខាន់ៗ និងវិធានការគន្លឹះនានា ព្រមទាំងបន្តជំរុញយ៉ាងសកម្មនូវរាល់កំណែទម្រង់រដ្ឋស៊ីជម្រៅរបស់ខ្លួនលើគ្រប់វិស័យ ដោយប្រកាន់យកអភិបាលកិច្ចល្អជាស្នូល។ ដំណើរការអនុវត្តលទ្ធិប្រជាធិបតេយ្យ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានពង្រឹង និងពង្រីកឥតឈប់ឈរ និងកំពុងបន្តដំណើរទៅមុខដោយរលូនតាមគន្លងនីតិរដ្ឋ។

ស្របតាមជំហានទៅមុខដ៏ស្វាហាប់ និងភាពទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល ព្រឹទ្ធសភាសូមគាំទ្រពេញទំហឹងដល់ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីធានាការអនុវត្តដោយជោគជ័យនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព។ ព្រឹទ្ធសភាមានជំនឿជឿជាក់ថា ក្រោមពន្លឺនៃកំណែទម្រង់លើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល អាណត្តិថ្មី ការអនុវត្តច្បាប់ និងគោលនយោបាយទាំងឡាយនឹងប្រព្រឹត្តទៅកាន់តែល្អប្រពៃ ជាគុណ

ប្រយោជន៍ដល់ការពង្រឹង ពង្រីកអភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាព និងការកសាងកម្ពុជាជានីតិរដ្ឋប្រកបដោយការអភិវឌ្ឍ និងចីរភាពយូរអង្វែង។

## III- សេចក្តីសន្និដ្ឋាន

ក្នុងអំឡុងពេលបីខែនៃចន្លោះសម័យប្រជុំព្រឹទ្ធសភាលើកទី២ និងលើកទី៣នេះ ថ្នាក់ដឹកនាំគណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការ ក្រុមភូមិភាគ ក្រុមសមាជិកាព្រឹទ្ធសភា និងសមាជិក សមាជិកាព្រឹទ្ធសភា បានរួមគ្នាខិតខំបំពេញភារកិច្ចរៀងៗខ្លួន ហើយសម្រេចបានលទ្ធផលផ្លែផ្កាជាគុណប្រយោជន៍ដល់ជាតិ និងប្រជាពលរដ្ឋយើង។

គណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានា ដែលជារចនាសម្ព័ន្ធនយោបាយរបស់ព្រឹទ្ធសភា បានចុះជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ក្រោមជាតិយ៉ាងសកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារតាមវិស័យ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ជាពិសេសជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតួអង្គសំខាន់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងបានចុះសួរសុខទុក្ខ ដោះស្រាយសំណូមពរ និងសំណើផ្សេងៗ របស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។

ឆ្លៀតក្នុងឱកាសនេះ ព្រឹទ្ធសភាសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្រដ៏ថ្លៃថ្លាពីស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដែលបានផ្តល់កិច្ចសហការល្អ បង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង ជូនគណៈកម្មការនានានៃព្រឹទ្ធសភា ក្រុមភូមិភាគ ក្រុមសមាជិកា និងសមាជិក សមាជិកាព្រឹទ្ធសភាទាំងអស់ បានជួបសំណេះសំណាល ប្រាស្រ័យការងារ និងសួរសុខទុក្ខប្រជាពលរដ្ឋនៅតាមភូមិភាគនានា។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែ ចេត្រ ឆ្នាំ រោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២៥

**ជ.គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា**

**ប្រធានព្រឹទ្ធសភា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**